# យើងជឿលើសេរីភាពខាងសាសនា និងមនសិការ

សូមឆ្លើយសំណួរខាងក្រោមនេះ ។

- តើអ្នកបានពិភាក្សាអំពីសាសនា ឬជំនឿខាងវិញ្ញាណជាមួយនរណាម្នាក់ដែលមានជំនឿខុសពីអ្នកនៅពេលណា ?

- តើពួកគេបានឆ្លើយតបចំពោះជំនឿរបស់អ្នកយ៉ាងដូចម្ដេច ? តើអ្នកឆ្លើយតបនឹងជំនឿរបស់ពួកគេដោយរបៀបណា ?

សូមពិចារណាអំពីសាច់រឿងខាងក្រោម ។

លៀមគឺជាសមាជិកក្រុមបាល់ទាត់របស់សាលាគាត់ ។ សមាជិកក្រុមរបស់គាត់ម្នាក់ឈ្មោះហ្សេន មានពិធីសាសនាផ្ទាល់ខ្លួនដែលគាត់ធ្វើមុនពេលប្រកួតម្ដងៗ ។ ហ្សេនគឺជាមនុស្សតែម្នាក់គត់ក្នុងក្រុមដែលកាន់សាសនារបស់គាត់ ។ សមាជិកក្រុមផ្សេងទៀតបានកត់សម្គាល់ឃើញអ្វីដែលហ្សេនធ្វើ និងបានចាប់ផ្ដើមសើចចំអកគាត់អំពីរឿងនេះ ។ លៀមដឹងថាសាសនារបស់ហ្សេន ពេលខ្លះមនុស្សនៅក្នុងសហគមន៍ឃើញថាវាគឺជារឿងអវិជ្ជមាន ។

សិក្សាឯកសារខាងក្រោមនេះ ដោយគិតអំពីរបៀបដែលវាអាចអនុវត្តចំពោះស្ថានភាពរបស់លៀម និងចំពោះការប្រាស្រ័យទាក់ទងរបស់អ្នកជាមួយមនុស្សដែលមានជំជឿខុសពីអ្នក ។

អាលម៉ា ៣០:៧–៩

មាត្រានៃសេចក្ដីជំនឿ ១:១១

ព្យាការី យ៉ូសែប ស្ម៊ីធ ( ឆ្នាំ ១៨០៥–១៨៤៤ ) បានបង្រៀន ៖



> ប្រសិនបើវាបង្ហាញថា ខ្ញុំបានស្ម័គ្រចិត្តស៊ូស្លាប់ដើម្បី« មរមន »ខ្ញុំមានចិត្តក្លាហាននឹងប្រកាសចំពោះស្ថានសួគ៌ថា ខ្ញុំពិតជាត្រៀមខ្លួនជាស្រេចដើម្បីស្លាប់ក្នុងការការពារសិទ្ធិរបស់ពួកប្រែសប៊ីធារាន ពួកបាទីស្ទ ឬបុរសល្អនៃនិកាយផ្សេងទៀត ដ្បិតគោលការណ៍តែមួយដែលនឹងជាន់ឈ្លីសិទ្ធិនៃពួកបរិសុទ្ធថ្ងៃចុងក្រោយក៏នឹងជាន់ឈ្លីសិទ្ធិ . . . នៃនិកាយណាមួយទៀតដែលពុំសូវមានប្រជាប្រិយភាព និងមានភាពទន់ខ្សោយពេកក្នុងការការពារខ្លួនផងដែរ ។
>
> នេះជាក្ដីស្រឡាញ់នៃសេរីភាព ដែលបំផុសគំនិតព្រលឹងខ្ញុំ—គឺសេរីភាពខាងសង្គម និងខាងសាសនាចំពោះពូជសាសន៍មនុស្សទាំងពួង ។
> ( *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ ២០០៧ ] ទំព័រ ៣៤៥ )

- តើអ្នកអាចចែកចាយអ្វីខ្លះជាមួយលៀម ដែលអាចជួយគាត់ឲ្យឆ្លើយតបទៅនឹងស្ថានភាពរបស់គាត់បាន ?

- តើអ្នកបានរៀនអ្វីខ្លះអំពីរបៀបដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទចង់ឲ្យអ្នកប្រព្រឹត្តចំពោះអស់អ្នកដែលជឿខុសពីអ្នក ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_463-2